**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

សាលាដំបូងរាជធានីភ្នំពេញ

**តុលាការរដ្ឋប្បវេណី**

-សំណុំរឿងរដ្ឋប្បវេណីលេខ: ១៦៦១
ចុះថ្ងៃទី១៣ ខែតុលា ឆ្នាំ២០២២
-សាលក្រមលេខ ៥១ "ជ"
ចុះថ្ងៃទី១៩ ខែមករា ឆ្នាំ២០២៣

**សាលក្រម**
**ក្នុងនាមប្រជារាស្ត្រខ្មែរ**
**សាលាដំបូងរាជធានីភ្នំពេញ**

បានបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់នៅថ្ងៃទី១៩ ខែមករា ឆ្នាំ២០២៣ ។

**ចៅក្រមជំនុំជម្រះ**

-លោក [redacted] ជាចៅក្រមនៃសាលាដំបូងរាជធានីភ្នំពេញ

**ក្រឡាបញ្ជី**

-លោកស្រី [redacted] ជាក្រឡាបញ្ជីនៃសាលាដំបូងរាជធានីភ្នំពេញ

**-រវាងដើមចោទ៖** ឈ្មោះ [redacted]សុផា ភេទស្រី កើតនៅឆ្នាំ១៩៨៨ មានទីលំនៅសព្វថ្ងៃនៅផ្ទះលេខ[redacted] ។

ដោយមានកញ្ញា [redacted] ជាមេធាវីតំណាងអាណត្តិ ។

**-និងចុងចម្លើយ៖** ឈ្មោះ [redacted] សេរីវុទ្ធ ភេទប្រុស កើតនៅឆ្នាំ១៩៨៣ ជាតិខ្មែរ មានទីលំនៅសព្វថ្ងៃស្នាក់នៅ [redacted] ។

## I. អង្គហេតុ និងចំណុចវិវាទ

**ក.ខ្លឹមសារនៃសាលក្រមដែលដើមចោទទាមទារឱ្យតុលាការចេញ:**

១-សុំលែងលះជាមួយប្តីឈ្មោះ [redacted]សេរីវុទ្ធ ។

២-ប្រគល់អំណាចមេបាលើកូនឈ្មោះ [redacted] សុផាម៉ានិច ភេទស្រី កើតនៅថ្ងៃទី០២ ខែកុម្ភៈ ឆ្នាំ២០២១ ឱ្យទៅដើមចោទឈ្មោះ [redacted]សុផា ។

៣-ប្រគល់ប្រាក់អាហារកាតព្វកិច្ចក្នុងការគ្រប់គ្រងថែរក្សាកូនចំនួន៤០០,០០០៛ (សែសិបម៉ឺនរៀល) ក្នុង១ខែឱ្យទៅដើមចោទឈ្មោះ [redacted]សុផា រហូតដល់កូនមាននីតិភាព ។

៤-ប្រាក់ប្រដាប់ក្ដីជាបន្ទុករបស់ចុងចម្លើយ ។

**ខ.ការពន្យល់ត្រួសៗអំពីរឿងក្ដី**

ខ.១-កាលពីអំឡុងខែមីនា ឆ្នាំ២០២០ នាងខ្ញុំឈ្មោះ [redacted] សុផា និងចុងចម្លើយឈ្មោះ [redacted]សេរីវុទ្ធ បានរួមរស់ជាមួយគ្នាជាដោយមានកូនចំនួន១នាក់ឈ្មោះ [redacted] សុផាម៉ានិច ភេទស្រី កើតនៅថ្ងៃទី០២ ខែកុម្ភៈ ឆ្នាំ២០២១ ។ លុះដល់ឆ្នាំ២០២១ នាងខ្ញុំនិងចុងចម្លើយឈ្មោះ [redacted] សេរីវុទ្ធ បានទៅចុះសំបុត្រអាពាហ៍ពិពាហ៍ត្រឹមត្រូវតាមច្បាប់ ក្នុងអំឡុងពេលនៃចំណងអាពាហ៍ពិពាហ៍នាងខ្ញុំ និងចុងចម្លើយឈ្មោះ [redacted] សេរីវុទ្ធ ពុំមានទ្រព្យរួម និងបំណុលរួមឡើយ ។ លុះដល់អំឡុងខែមីនា ឆ្នាំ២០២២ នាងខ្ញុំនិងចុងចម្លើយឈ្មោះ [redacted] សេរីវុទ្ធ តែងតែមានការទាស់ទែងឈ្លោះប្រកែកគ្នាមានភាពរកាំរកូស និងខ្វែងគំនិតគ្នាហើយបានចាកចេញពីផ្ទះដោយគ្មានមូលហេតុដោយមិនបានខ្វល់ខ្វាយពីសុខទុក្ខប្រពន្ធកូន និងមិនបានផ្ដល់ប្រាក់សម្រាប់ទំនុកបំរ៉ុងគ្រួសារប្រពន្ធកូនឡើយដែលរហូតមកដល់បច្ចុប្បន្ននេះគឺមានរយៈពេលចំនួន៧ខែមកហើយ ដោយទុកឱ្យនាងខ្ញុំដែលជាប្រពន្ធចិញ្ចឹមបីបាច់ថែរក្សាកូនស្រីដែលទើបតែអាយុ១ខួបជាងតែម្នាក់ឯង ដែលទង្វើលទាំងអស់នេះបានធ្វើឱ្យនាងខ្ញុំអស់មនោសញ្ចេតនាក្នុងការរស់នៅជាប្ដីប្រពន្ធតទៅទៀតបានឡើយ ។

**គ.ការអះអាងរបស់គូភាគី**

**គ.១-ការអះអាងដោយដើមចោទ**

-ដើមចោទឈ្មោះ [redacted]សុជា ភេទស្រី ដោយមានកញ្ញា [redacted]ជាមេធាវីតំណាងអាណត្តិបានថ្លែងការណ៍ថា៖ នាងខ្ញុំបានរៀបអាពាហ៍ពិពាហ៍ជាមួយឈ្មោះ [redacted] សេរីវុទ្ធ និងបានចុះសំបុត្រអាពាហ៍ពិពាហ៍លេខ ២៥២ ចុះថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ២០២១ ចេញដោយលោកចៅសង្កាត់ផង្កា ត្រឹមត្រូវតាមច្បាប់ក្រោយពីរស់នៅជាមួយគ្នាពួកខ្ញុំបង្កើតបានកូនម្នាក់ឈ្មោះ [redacted]សុផាម៉ានិច ភេទស្រី កើតនៅថ្ងៃទី០២ ខែកុម្ភៈ ឆ្នាំ២០២១ ក្រោយពីបានរស់នៅជាមួយគ្នាមកពួកខ្ញុំរស់នៅមិនចុះសម្រុងនិងគ្នាទេ ដោយមានការឈ្លោះប្រកែកជារឿយៗជាហេតុធ្វើឱ្យប្តីឈ្មោះ [redacted] សេរីវុទ្ធ ចុះចោលផ្ទះរហូត ហើយសព្វថ្ងៃពួកខ្ញុំរស់នៅបែកគ្នាប្រហែល៩ខែមកហើយជាហេតុធ្វើឱ្យខ្ញុំអស់មនោសញ្ចេតនាក្នុងការរស់នៅជាមួយគ្នាតទៅទៀត នាងខ្ញុំក៏សម្រេចចិត្តដាក់ពាក្យបណ្តឹងមកតុលាការសុំលែងលះតាមច្បាប់តែម្តង ។

នាងខ្ញុំសំណូមពរស្នើសុំឱ្យតុលាការចេញសាលក្រមលែងលះតាមច្បាប់ , សុំគ្រប់គ្រងកូនឈ្មោះ [redacted]សុផាម៉ានិច ភេទស្រី កើតនៅថ្ងៃទី០២ ខែកុម្ភៈ ឆ្នាំ២០២១ ចិញ្ចឹមបីបាច់ថែរក្សារហូតដល់កូនមាននីតិភាព និងឱ្យចុងចម្លើយឈ្មោះ[redacted]សេរីវុទ្ធ បង់ប្រាក់អាហារកិច្ចចិញ្ចឹមកូនតាមលទ្ធភាព ។

**៣.២-ការអះអាងដោយចុងចម្លើយ**

-តុលាការបានចេញដីកាកោះហៅចុងចម្លើយឈ្មោះ [redacted] សេរីវុទ្ធ តាមនីតិវិធី និងបានធ្វើការបញ្ជូនដល់ផ្ទះតាមនីតិវិធីរួចហើយ តែដល់ពេលថ្ងៃកំណត់ចុងចម្លើយមិនព្រមចូលខ្លួនមកតាមការណាត់របស់សាលាដំបូងនេះទេ ដូច្នេះសាលាដំបូងអាចបន្តនីតិវិធីដោយកំបាំងមុខបាន ។

**៤.ចំណុចគ្មានវិវាទ:** "គ្មាន"

**៥.ចំណុចវិវាទ:** "គ្មាន"

## II.ការពិនិត្យភស្តុតាង

**១. ភស្តុតាងជាឯកសាររបស់ដើមចោទមានជាអាទិ៍**

**១.១.ឯកសារ៖** សំបុត្រអាពាហ៍ពិពាហ៍លេខ២៥២ ចុះថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ២០២១ ចេញដោយលោកចៅសង្កាត់ផង្កា ។

**១.២.ឯកសារ៖** សំបុត្រកំណើតលេខលេខ១២២ ចុះថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ២០២១ របស់កូនស្រីឈ្មោះ [redacted]សុផាម៉ានិច ចេញដោយចៅសង្កាត់ផង្កា ។

**១.៣.ឯកសារ៖** អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែររបស់ឈ្មោះ [redacted]សុជា ។

**១.៤.ឯកសារ៖**អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែររបស់ឈ្មោះ[redacted]សេរីវុទ្ធ ។

**២. ភស្តុតាងជាឯកសាររបស់ចុងចម្លើយ**

**២.១.ឯកសារ៖** "គ្មាន" ។

**៣.ការសាកសួរសាក្សី:** គ្មាន ។

## សំអាងហេតុ

ផ្អែកតាមលទ្ធផលនៃការទាញហេតុផលដោយផ្ទាល់មាត់ និងការពិនិត្យភស្តុតាងតុលាការយល់ឃើញថា៖

១-តាមការអះអាងរបស់ដើមចោទឈ្មោះ[redacted]សុជា ភេទស្រី ដោយមានកញ្ញា [redacted]ជាមេធាវីតំណាងអាណត្តិបានថ្លែងការណ៍ថា៖ ខ្លួនបានរៀបអាពាហ៍ពិពាហ៍ជាមួយឈ្មោះ [redacted] សេរីវុទ្ធ និងបានចុះសំបុត្រអាពាហ៍ពិពាហ៍លេខ២៥២ ចុះថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ២០២១ ចេញដោយលោកចៅសង្កាត់ផង្កា ត្រឹមត្រូវតាមច្បាប់ក្រោយពីរស់នៅជាមួយគ្នាពួកខ្លួនបង្កើតបានកូនម្នាក់ឈ្មោះ[redacted]សុផាម៉ានិច ភេទស្រី កើតនៅថ្ងៃទី០២ ខែកុម្ភៈ ឆ្នាំ២០២១ ក្រោយពីបានរស់នៅជាមួយគ្នាមកពួកខ្លួនរស់នៅមិនចុះសម្រុងនិងគ្នាទេដោយមានការឈ្លោះប្រកែកជារឿយៗជាហេតុធ្វើឱ្យប្តីឈ្មោះ [redacted] សេរីវុទ្ធ ចុះចោលផ្ទះរហូតហើយសព្វថ្ងៃពួកខ្លួនរស់នៅបែកគ្នាប្រហែល៩ខែមក



Scanned with CamScanner

ហើយជាហេតុធ្វើឱ្យខ្លួនអស់មនោសញ្ចេតនាក្នុងការរស់នៅជាមួយគ្នាតទៅទៀតខ្លួនក៏សម្រេចចិត្តដាក់ពាក្យបណ្តឹងមកតុលាការសុំលែងលះតាមច្បាប់តែម្តង ។

២-ផ្អែកតាមការទទួលស្គាល់របស់គូភាគីមានសំបុត្រអាពាហ៍ពិពាហ៍លេខ២៥២ ចុះថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ២០២១ ចេញដោយលោកចៅសង្កាត់ដង្កោបញ្ជាក់ថាដើមចោទឈ្មោះ [redacted] សុផា និងចុងចម្លើយឈ្មោះ [redacted] សេរីវុទ្ធ ពិតជាសហព័ទ្ធនិងគ្នាពិតប្រាកដមែន ។ ដូច្នេះការប្តឹងសុំលែងលះរបស់ដើមចោទ មានអត្ថិភាព ដើម្បីឱ្យតុលាការយកមកពិចារណានិងសម្រេចចេញសាលក្រមជាសមត្ថកិច្ច ។

៣-ក្នុងចំណងអាពាហ៍ពិពាហ៍នេះគូភាគីនេះមានកូន១នាក់ឈ្មោះ [redacted] សុផាម៉ានិច ភេទស្រី កើតនៅថ្ងៃទី០២ ខែកុម្ភៈ ឆ្នាំ២០២១ មានសំបុត្រកំណើតលេខលេខ១២២ ចុះថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ២០២១ ចេញដោយចៅសង្កាត់ដង្កោ ជាអនីតិជននៅឡើយ ។

៤-ភាគីដើមចោទឈ្មោះ [redacted] សុផា សុំសិទ្ធិគ្រប់គ្រងកូនឈ្មោះ [redacted] សុផាម៉ានិច ភេទស្រី កើតនៅថ្ងៃទី០២ ខែកុម្ភៈ ឆ្នាំ២០២១ រហូតដល់កូនមាននីតិភាពតុលាការគប្បីពិចារណានិងសម្រេច ។

៥-ភាគីដើមចោទឈ្មោះ [redacted] សុផា សុំឱ្យភាគីចុងចម្លើយឈ្មោះ [redacted] សេរីវុទ្ធ បង់ប្រាក់អាហារកិច្ចចិញ្ចឹមកូនតាមលទ្ធភាព គប្បីតុលាការសម្រេចតាមការស្នើសុំ ។

៦-ប្រាក់ប្រដាប់ក្តីផ្អែកតាមមាត្រា៦៤ នៃក្រមនីតិវិធីរដ្ឋប្បវេណីគប្បីឱ្យចុងចម្លើយជាអ្នកទទួលបន្ទុក ។

## សេចក្តីសម្រេចបញ្ចប់

១. លែងលះរវាងដើមចោទឈ្មោះ [redacted] សុផា និងចុងចម្លើយឈ្មោះ [redacted] សេរីវុទ្ធ ។

២.កំណត់យកដើមចោទឈ្មោះ [redacted] សុផា ជាអ្នកមានអំណាចមេបាលើកូនឈ្មោះ [redacted] សុផាម៉ានិច ភេទស្រី កើតនៅថ្ងៃទី០២ ខែកុម្ភៈ ឆ្នាំ២០២១ មានសំបុត្រកំណើតលេខលេខ១២២ ចុះថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ២០២១ ចេញដោយចៅសង្កាត់ដង្កោ ។

-ភាគីដែលមិនមានសិទ្ធិអំណាចមេបាមានសិទ្ធិចូលជួបប្រាស្រ័យទាក់ទងជាមួយកូន ត្រូវបង់ប្រាក់អាហាការកិច្ចចិញ្ចឹមតាមលទ្ធភាពរហូតដល់កូនមាននីតិភាព ហើយភាគីដែលមានអំណាចមេបាត្រូវបង្កលក្ខណៈងាយស្រួលដល់ភាគីម្ខាងទៀត ។

៣.ប្រាក់ប្រដាប់ក្តីជាបន្ទុករបស់ចុងចម្លើយ ។

-សាលក្រមនេះបានបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់ និងប្រកាសជាសាធារណៈនៅថ្ងៃទី១៩ ខែមករា ឆ្នាំ២០២៣ ។

**ចៅក្រមជំនុំជម្រះ**

ហត្ថលេខា និងត្រា

[redacted]

**បានឃើញ**

**ចៅក្រមជំនុំជម្រះ**

[redacted]

(បានចម្លងចេញត្រឹមត្រូវតាមច្បាប់ដើម)

ថ្ងៃព្រហស្បតិ៍ ១៣រោច ខែបុស្ស ឆ្នាំខាល ចត្វាស័ក ព.ស ២៥៦៦

រាជធានីភ្នំពេញ,ថ្ងៃទី១៩ ខែមករា ឆ្នាំ២០២៣

**ក្រឡាបញ្ជី**

[redacted]



Scanned with CamScanner